■改編自:新北市教育局陪你快樂學東埔寨語

□自編_

107 年新北市各級學校東南亞語文競賽

團體朗讀文稿 B 東埔寨 語 國高中 組

# ទៅផ្ទះយាយ

សុខានិងម៉ាក់,បងស្រី,ប្អូនស្រី,ជិះយន្តហោះទៅផ្ទះយាយប្រទេសកម្ពុជាទាំង

អស់គ្នា។

សុខា:ម៉ាក់តើស្រុកខ្មែរមានមធ្យោបាយធ្វើដំណើរអ្វីខ្លះ?

ម៉ាក់:នៅស្រុកខ្មែរមធ្យោបាយធ្វើដំណើរខុសគ្នាពីតៃវ៉ាន់

សុខា:តើខុសគ្នាដូចម្តេច?

នៅជនបទមានរទេះសេះ រទេះគោ រទេះកង់បីរឺម៉ូតូតុកតុក។

បងស្រីចុះនៅក្នុងទីក្រុង

វិញ?

ម៉ាក់:ឥឡូវក៏មានម៉ូតូ,ឡានដែរ។

ប្អូនស្រី:អញ្ចឹងត្រូវជិះឡានអ្វីទៅផ្ទះយាយ?

ម៉ាក់:ពួកយើងជិះឡានទៅ។

ម៉ាក់:នៅមួយ ម៉ោងទៀតទើបឡានមក

ដល់។

អ្នកទាំងអស់គ្នាញុំាគុយទាវសិនទៅ។

សុខា:ខ្ញុំក៏ត្រូវតែញុំាសម្លរបញ្ចុកសម្លរខ្មែររបស់ប្រទេសកម្ពុជា។

ខ្ទិះដូងឈ្ងុយណាស់អ៊ំ។

បងស្រីប្អូនស្រី:ពួកយើងត្រូវតែញុំានំប៉័ងដាក់សាច់ដែរស្រួយនិងដ៏មានរស់ជាតិឈ្ងុយឆ្ងាញ់ណាស់

ញុំាបាយរួច,ជិះឡានផ្លូវឆ្ងាយរួចហើយដូរជិះរទេះកង់បីទៀតបានដល់ផ្ទះយា

យ។

សុខា:ផ្ទះតាជាផ្ទះប្រក់

គ្បឿងបុរាណបីខ្នងជាប់គ្នាចុះផ្ទះយាយជាផ្ទះប្រភេទណាដែរ?

ម៉ាក់:ផ្ទះដែលយាយស្នាក់នៅជាផ្ទះខ្ពស់។

ប្អូនស្រី:ម៉ាក់តើអ្វីជាផ្ទះខ្ពស់?

បងស្រី:ខ្ញុំដឹងជាផ្ទះដែលមានលក្ខណៈពិសេសក្នុងការសាងសង់

តំបូលប្រក់គ្បឿងមានក្បាច់រចនា

ហើយយកឬស្សីខ្ចីមមកបិតធ្វើជញ្ជាំងមនុស្សរស់នៅខាងលើ។

ឯខាងក្រោមដាក់ឥវ៉ាន់និងចិញ្ចឹមសត្វ។

ម៉ាក់:បងស្រីនិយាយត្រូវ,នៅក្បែរផ្ទះមានដាំដើមស្វាយនិងដើមចេក។

សុខា:ខាងមុខមានផ្ទះខ្ពស់នេះជាផ្ទះយាយមែនទេ?

ម៉ាក់:មែនហើយ,យាយកំពុងតែបក់ដៃ។

បងស្រី សុខា ប្អូនស្រី:ជំរាបសួរយាយ ពួកខ្ញុំនឹកយាយណាស់!

យាយមើលមកពួកយើង,ក្នុងទឹកមុខញញឹមប្រកបដោយព្រហ្មវិហាធម៌។ផ្ទះ

យាយពិតជាល្អមែន។